អេស៊ីលីដា ACLEDA BANK

# សេចក្តីជូនដំណឹង
## ស្តីពី
## ការធ្វើវិសោធនកម្មលក្ខន្តិកៈរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (“ធនាគារ អេស៊ីលីដា”) ជាធនាគារពាណិជ្ជទីមួយដែលបានបោះផ្សាយមូលបត្រជាសាធារណៈនៅផ្សារមូលបត្រកម្ពុជា (“ផមក”) មានកិត្តិយស សូមជម្រាបជូនដំណឹងដល់សាធារណជន និងវិនិយោគិនទាំងអស់ មេត្តាជ្រាបថា ធនាគារជាតិ នៃ កម្ពុជា និងក្រសួងពាណិជ្ជកម្ម បានទទួលស្គាល់ និងអនុម័តការធ្វើវិសោធនកម្មលក្ខន្តិកៈរបស់ ធនាគារ អេស៊ីលីដា ដូចខាងក្រោម៖

**១. ការផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល**

យោងសេចក្តីជូនដំណឹងស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាភិបាលធនាគារ អេស៊ីលីដា ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅលើផ្សារមូលបត្រកម្ពុជា ធនាគារ អេស៊ីលីដា បានធ្វើវិសោធនកម្មឧបសម្ព័ន្ធទី១ ស្តីពី សមាសភាពក្រុមប្រឹក្សាភិបាលនៃលក្ខន្តិកៈរបស់ ធនាគារ អេស៊ីលីដា។ ដូច្នេះ សមាសភាពក្រុមប្រឹក្សាភិបាលថ្មី មានដូចខាងក្រោម៖

| មុនពេលវិសោធនកម្ម | | ក្រោយពេលវិសោធនកម្ម | |
|---|---|---|---|
| លោក ឆាយ សឿន | ប្រធានក្រុមប្រឹក្សាភិបាល | លោកស្រី គឹម សុធាវី | ប្រធានក្រុមប្រឹក្សាភិបាល |
| បណ្ឌិត អ៊ិន ចាន់នី | អភិបាលប្រតិបត្តិ | បណ្ឌិត អ៊ិន ចាន់នី | អភិបាលប្រតិបត្តិ |
| លោក Pieter Kooi | អភិបាលឯករាជ្យ | លោក Pieter Kooi | អភិបាលឯករាជ្យ |
| លោកស្រី ភូរិ រតនា | អភិបាលឯករាជ្យ | លោកស្រី ភូរិ រតនា | អភិបាលឯករាជ្យ |
| បណ្ឌិត ហេង ឌីណា | អភិបាលឯករាជ្យ | បណ្ឌិត ហេង ឌីណា | អភិបាលឯករាជ្យ |
| លោក កាយ ឡូត | អភិបាលឯករាជ្យ | លោក កាយ ឡូត | អភិបាលឯករាជ្យ |
| បណ្ឌិត Albertus Bruggink | អភិបាលមិនប្រតិបត្តិ | បណ្ឌិត Albertus Bruggink | អភិបាលមិនប្រតិបត្តិ |
| លោក Olivier Louis Roger Fouchet | អភិបាលមិនប្រតិបត្តិ | លោក Olivier Louis Roger Fouchet | អភិបាលមិនប្រតិបត្តិ |
| លោក Kaoru Furuya | អភិបាលមិនប្រតិបត្តិ | លោក Kaoru Furuya | អភិបាលមិនប្រតិបត្តិ |
| លោកស្រី គឹម សុធាវី | អភិបាលប្រតិបត្តិ | | |

**២. វិសោធនកម្មលក្ខន្តិកៈ មាត្រា២៩ អាណត្តិរបស់សមាជិកក្រុមប្រឹក្សាភិបាល**

ការធ្វើវិសោធនកម្មលក្ខន្តិកៈ មាត្រា២៩ អាណត្តិរបស់សមាជិកក្រុមប្រឹក្សាភិបាល ដោយបានកែសម្រួលអំពីការបំពេញតំណែងដែលទំនេរកើតឡើងនៅក្នុងក្រុមប្រឹក្សាភិបាល។

**៣. វិសោធនកម្មលក្ខន្តិកៈ មាត្រា៤០ គណៈកម្មាធិការនានានៃក្រុមប្រឹក្សាភិបាល**

ការធ្វើវិសោធនកម្មលក្ខន្តិកៈ មាត្រា៤០ គណៈកម្មាធិការនានានៃក្រុមប្រឹក្សាភិបាល ដោយបានកែប្រែឈ្មោះ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ទៅជា គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា។

**៤. វិសោធនកម្មលក្ខន្តិកៈ មាត្រា៤២ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា**

ការធ្វើវិសោធនកម្មលក្ខន្តិកៈ មាត្រា៤២ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ដោយបានកែប្រែឈ្មោះ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ទៅជា គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា និងបានកែសម្រួលតួនាទី និងភារកិច្ចមួយចំនួនរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងវិនិយោគិនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន៕

ថ្ងៃអង្គារ ១២កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៦

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**